**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៣០ សលង**

# សារជូនពរ
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ជូនចំពោះ
## យោធិនទាំងអស់ នៃកងពលតូចលេខ៧០

***ឯកឧត្តម មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងពលតូចលេខ៧០ ជាទីស្នេហា!***

ថ្ងៃនេះក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយនិងសូមចូលរួមអបអរសាទរយ៉ាងកក់ក្តៅ ជាមួយមេបញ្ជាការ មេបញ្ជាការរង និងយោធិនទាំងអស់នៃកងពលតូចលេខ៧០ ក្នុងឱកាសខួបលើកទី២៥ ថ្ងៃកំណើតកងពលតូចលេខ៧០ ( ១៥ តុលា ១៩៩៤ - ១៥ តុលា ២០១៩ ) នេះ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ខ្ញុំសូមផ្ញើជូននូវការសាកសួរសុខទុក្ខជូនចំពោះថ្នាក់ដឹកនាំ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៅកងពលតូច៧០ ដោយសេចក្តីនឹករលឹក និងស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅ។ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងការលើកទឹកចិត្តដោយស្មោះចំពោះយោធិនទាំងអស់ ដែលជានិច្ចកាលតែងតែបានខិតខំព្យាយាមជម្នះឧបសគ្គ ប្រកៀកស្មាគ្នាយ៉ាងរឹងមាំ សាមគ្គីភាព ឯកភាពផ្ទៃក្នុង និងសហការបានល្អជាមួយបណ្តាកងឯកភាពទូទាំងកងយោធពលខេមរភូមិន្ទ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ក្នុងបុព្វហេតុការពារសន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដី និងរួមចំណែកដល់ដំណើរការអភិវឌ្ឍជាតិក្នុងពេលកន្លងមក ដែលជាពលិកម្មដ៏ធំធេង ដើម្បីជាតិមាតុភូមិ និងភាពសុខសាន្តរបស់ប្រជាជន ក្នុងខណៈពេលដែលប្រទេសមួយចំនួននៅក្នុងសកលលោកកំពុងប្រឈមនិងរងគ្រោះដោយសារសង្គ្រាម អំពើភេរវកម្ម និងព្រឹត្តិការណ៍អសន្តិសុខផ្សេងៗទៀត។

គ្រប់ស្នាដៃ និងសមិទ្ធផលជាច្រើនដែលកងពលតូចលេខ៧០ សម្រេចបាននាពេលកន្លងមកនេះ គឺពិតជាមិនអាចធ្វើបាននោះទេ បើសិនមិនមានការចូលរួមចំណែកពីយោធិនគ្រប់លំដាប់ថ្នាក់ ក្នុងការបំពេញភារកិច្ច ប្រកបដោយភាពអង់អាចក្លាហាន មោះមុត វិន័យម៉ឺងម៉ាត់ និងការប្តេជ្ញាទទួលខុសត្រូវនៅគ្រប់កាលៈទេសៈ និងគ្រប់ស្ថានភាព។

ជាមួយនឹងការអបអរសាទរខួបលើកទី២៥នៃថ្ងៃកំណើតកងពលតូចលេខ៧០ នាពេលនេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមោទនភាព និងមនោសញ្ចេតនារីករាយថ្លែងនូវសារលិខិតជូន ឯកឧត្តម **ឧត្តមសេនីយ៍ឯក ម៉ៅ សុផាន់** មេបញ្ជាការ កងពលតូចលេខ៧០ ក៏ដូចជាជូនចំពោះនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងន័យបង្ហាញអំពីឆន្ទៈគាំទ្រ និងជាការលើកទឹកចិត្តចំពោះការដឹកនាំបញ្ជាដ៏មោះមុត ការតស៊ូលះបង់ មានភក្តីភាព និងមនសិការខ្ពស់ ក្នុងបុព្វហេតុការពារថែរក្សាសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម ភាពសុខដុមរមនា និងភាពរីកចម្រើនលើគ្រប់វិស័យនៃប្រជាជាតិកម្ពុជាយើងទាំងមូល។

**នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់!**

ទោះបីជាយើងមានមោទនភាពចំពោះស្នាដៃ និងសមិទ្ធផលជាច្រើន ដែលសម្រេចបានមកហើយយ៉ាងណាក្ដី ប៉ុន្តែយើងទាំងអស់គ្នាក៏សុទ្ធតែបានជ្រួតជ្រាបថា ឆ្នាំ២០១៩នេះ បើទោះបីជាកម្ពុជាទទួលរងឥទ្ធិពលតិចតួច ឬ ដោយប្រយោលពីស្ថានការណ៍អសន្តិសុខរបស់ពិភពលោកក៏ដោយ បញ្ហាអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទនៅតែជាកម្មវត្ថុដ៏សំខាន់ប្រកបដោយគ្រោះថ្នាក់ គួបផ្សំនឹងភាពផុយស្រួយដែលបង្កឡើងដោយការវិវត្តប្រែប្រួលនៃសភាពការណ៍អន្តរជាតិ ការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចរបស់មហាអំណាច ការប៉ុនប៉ងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង បញ្ហាបដិវត្តន៍ពណ៌ ព្រមទាំងការគំរាមកំហែងលើឯករាជ្យ អធិតេយ្យ និងបូរណភាពទឹកដី ព្រមទាំងមហិច្ឆិតារបស់ជនក្បត់ជាតិ និងអ្នកនយោបាយមួយក្ដាប់តូច ដែលតាំបាច់ទាមទារឲ្យយើងបង្កើនការប្រុងប្រយ័ត្នខ្ពស់ត្រៀមវិធានការទប់ស្កាត់ប្រកបដោយភាពបត់បែន និងម្ចាស់ការ។

គោលដៅសំខាន់ពីរ នៃគោលនយោបាយការពារជាតិរបស់រាជរដ្ឋាភិបាល គឺការធ្វើឱ្យមានសន្តិភាព ស្ថិតស្ថេរយូរអង្វែង និងការកសាងឱកាសសម្រាប់ការអភិវឌ្ឍជាតិប្រកបដោយចីរភាព។ សន្តិភាព ស្ថិរភាពនយោបាយ និងភាពរីកលូតលាស់ផ្នែកសេដ្ឋកិច្ច ដែលកម្ពុជាកំពុងមានក្នុងពេលបច្ចុប្បន្ននេះ ក៏កំពុងតែផ្ដល់ឱកាសមួយសម្រាប់ការកសាង និងអភិវឌ្ឍសមត្ថភាពកងយោធពលខេមរភូមិន្ទផងដែរ។ ក្នុងន័យនេះ ចំពោះកងពលតូចលេខ៧០ ក៏ដូចជាបណ្ដាកងឯកភាពទូទាំងកងយោធពលខេមរភូមិន្ទ ត្រូវបន្តជំរុញយកចិត្តទុកដាក់លើការងារកែទម្រង់របស់ខ្លួន ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាកសាងពង្រឹងអង្គភាពឲ្យបានរឹងមាំលើគ្រប់វិស័យ ដែលជាមូលដ្ឋានដ៏ចាំបាច់ធានាឲ្យការដឹកនាំបញ្ជា ការកសាងកម្លាំង និងការពង្រឹងប្រៀបការពារជាតិរឹងមាំ។

រាជរដ្ឋាភិបាលកម្ពុជា សូមថ្លែងនូវការគាំទ្រ និងនៅតែបន្តយកចិត្តទុកដាក់ខ្ពស់លើការងារដោះស្រាយជីវភាព ថវិការបបឧបត្ថម្ភផ្សេងៗ និងការបំពាក់សម្ភារៈស្របតាមស្ថានភាពនៃសេដ្ឋកិច្ចជាតិ ព្រមទាំងការផ្ដល់នូវកិត្តិយស និងការគោរពដោយសេចក្ដីថ្លៃថ្នូរចំពោះកងយោធពលខេមរភូមិន្ទ ក្នុងន័យជាការតបស្នងដល់គុណូបការៈដ៏ឧត្តុងឧត្ដមរបស់កងយោធពលខេមរភូមិន្ទនៃយើង។

មុននឹងបញ្ចប់ ជំនួសមុខឲ្យរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី មេបញ្ជាការ មេបញ្ជាការរង នាយទាហាន ពលទាហានទាំងអស់ នៃកងពលតូចលេខ៧០ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១០ កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**